ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍កិច្ចប្រជុំ

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី០៧ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១ . ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២២

**២. ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាយ( Zoom )

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣.១ ប្រធានអង្គប្រជុំ ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៣.២ សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន២៥រូប និងតាមប្រព័ន្ធអនឡាយចំនួន៤៣រូប សរុបចំនួន៦៨រូប។

**៤. របៀបវារៈ៖**

៤.១ ពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាព នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ នៅកម្ពុជាក្នុងឆមាសទី១ ឆ្នាំ២០២២

៤.២ អំពីតួនាទីរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តួនាទីរបស់ក្រុមប្រឹក្សាបច្ចេកទេស និងតួនាទីក្រុមការងារយុទ្ធសាស្ត្រ៖

- ព្រះរាជក្រមលេខ នស /រកម/០៧០២/០១៥ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០២ប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍។
- អនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- សេចក្តីសម្រេចលេខ១៦២ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ស្តីពីក្រុមការងាររៀបចំត្រួតពិនិត្យវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ឆ្នាំ២០១៩-២០២៣។

៤.៣ សេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២

៤.៤ កិច្ចពិភាក្សាលើការអនុវត្តសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០២២ ។

**៥. លទ្ធផល ៖**

៥.១ ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត ប្រធានអង្គប្រជុំបានថ្លែងអំណរគុណដល់សមាជិកលេខាធិការដ្ឋានទាំងអស់ ដែលបានផ្តល់របាយការណ៍ទាន់ពេលវេលា ព្រមទាំងបានជម្រាបជូនដល់ សមាជិកក្រុមការងារ រកវិធីសាស្ត្រយ៉ាងណាអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានតាមផែនការកំណត់ និងត្រូវបានផ្តល់ការលើកទឹកចិត្ត ជាពិសេស៩៥ ទីមួយដែលមិនទាន់បានសម្រេចគោលដៅ។

៥.២ ប្រកាស ស្តីពីនិតិវិធីក្នុងការចំណាយថវិកា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលនឹងចេញនៅសប្តាហ៍ក្រោយ នឹងជួយសម្រួលដល់ការអនុវត្តសកម្មភាពនៅតាមបណ្តារាជធានី ខេត្ត

៥.៣ ជំរុញគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ន រាជធានី ខេត្ត ឱ្យអនុវត្តសេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

៥.៤ ក្រុមយុទ្ធសាស្ត្រទាំង៤ នឹងធ្វើការជាមួយដៃគូ ក្នុងការរៀបចំកិច្ចប្រជុំ ដែលអាចប្រព្រឹត្តទៅនៅថ្ងៃ ៣១ ខែសីហា ឆ្នាំ២០២២ បន្ទាប់ពីការត្រឡប់មកប្រទេសវិញរបស់ឯ.ឧ. ទេសរដ្ឋមន្ត្រី។

៥.៥ បានកំណត់សម្រាប់ការប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៨ ដោយកំណត់យកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២។

ថ្ងៃពុធ ១៤រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

**ប្រធានអង្គប្រជុំ**

**ស៊ុំ ផល្លា**